



សំណួរ ចម្លើយ QCM ភាគទី ៩

ប្រឡងចូលសាលាភូមិន្ទរដ្ឋបាល (ERA)

(មន្ត្រីជាន់ខ្ពស់ និង មន្ត្រីក្រមការ)

រដ្ឋបាលទូទៅ រដ្ឋបាលសាធារណៈ មុខងារសាធារណៈ
លិខិតបទដ្ឋាន សេដ្ឋកិច្ច ទំនាក់ទំនងអន្តរជាតិ អាស៊ាន...

១២១. ចំណាយបន្ទុកបុគ្គលិកសំដៅចំណាយលើ:

ក. បេសកកម្មក្នុងនិងក្រៅប្រទេស

ខ. ការទូទាត់ទិញសម្ភារៈការិយាល័យរបស់អង្គភាពថវិកា

គ. ឧបត្ថម្ភជូននិវត្តជន

ឃ. បៀវត្សសរុបនិងប្រាក់ឧបត្ថម្ភនានាសម្រាប់មន្ត្រីរាជការ 

១២២. លទ្ធកម្មគឺជាអ្វី?

ក. គឺជាចំណាយពីការលក់ ជួលសម្បទានរបស់អង្គភាពរដ្ឋ

ខ. គឺជាការទិញ ការជួសជុលនូវមុខសញ្ញាបរិមាណតិចតួច និងជាបន្ទាន់

គ. គឺជាការទិញ ឬការរកបាននូវទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា តាមរយៈវិធីសាស្ត្រ និងនីតិវិធីដែលបានកំណត់ក្នុង "វិធាននិងបទប្បញ្ញត្តិលទ្ធកម្មសាធារណៈ"

ឃ. គឺជាការរកបាននូវអំណោយដែលបានទទួលពីបណ្តាប្រទេសនានា

១២៣. សសរស្តម្ភសំខាន់ៗរបស់សហគមន៍អាស៊ានសម្រាប់អនុវត្តពីឆ្នាំ ២០១៥ គឺមានៈ

ក. សហគមន៍កសិកម្ម សហគមន៍ឧស្សាហកម្ម សហគមន៍សេវាកម្ម

ខ. សហគមន៍កសិកម្ម សហគមន៍ឧស្សាហកម្ម សហគមន៍ទេសចរណ៍

គ. សហគមន៍សន្តិសុខនយោបាយ សហគមន៍សេដ្ឋកិច្ច សហគមន៍សង្គមវប្បធម៌ 

ឃ. សហគមន៍សន្តិសុខនយោបាយ សហគមន៍សេដ្ឋកិច្ច សហគមន៍បរិស្ថាន

១២៤. គណនេយ្យករសាធារណៈសំដៅទៅលើស្ថាប័ន:

ក. រតនាគារជាតិ និងរតនាគាររាជធានី ខេត្ត

ខ. ការិយាល័យគណនេយ្យ ក្រសួង ស្ថាប័ន

គ. អាជ្ញាធរសវនកម្មជាតិ

ឃ. ធនាគារជាតិនៃកម្ពុជា

១២៥. សេដ្ឋកិច្ចគឺជាការសិក្សា

ក. នៃរបៀបធ្វើការវិនិយោគក្នុងទីផ្សារភាគហ៊ុន

ខ. អំពីថាតើធនធានកម្រត្រូវប្រើប្រាស់យ៉ាងដូចម្តេច

គ. អំពីតួនាទីរបស់លុយក្នុងទីផ្សារ

ឃ. អំពីថាតើមន្ត្រីរដ្ឋាភិបាលជាអ្នកសម្រេចនូវទំនិញ និងសេវាកម្មអ្វីដែលត្រូវផលិត

១២៦. ពាក្យថា "វិនិយោគ" បានប្រើប្រាស់ដោយអ្នកសេដ្ឋកិច្ចសំដៅលើ៖

ក. ការបង្កើតមូលធនថ្មី

ខ. ការទិញភាគហ៊ុន

គ. ការសន្សំរបស់គ្រួសារមួយ

ឃ. ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន

១២៧. អតិថរណាជ:ឥទ្ធិពលទៅលើ:

ក. តែអ្នកលក់ប៉ុណ្ណោះ

ខ. តែកសិករប៉ុណ្ណោះ

គ. ប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេស 

ឃ. តែក្នាក់ងារដ្ឋប៉ុណ្ណោះ

១២៨. កត្តាមួយដែលមិនមែនជាកត្តាជំរុញ សម្រាប់ជោគជ័យរបស់អង្គភាពក្នុងនវនុវត្តន៍គឺ:

ក. ការអនុវត្តការងារជាបុគ្គល

ខ. ការច្នៃប្រឌិតរបស់បុគ្គលិក

គ. ការបណ្តុះបណ្តាលរបស់បុគ្គលិក

ឃ. ការលើកទឹកចិត្តបុគ្គលិក

១២៩. កត្តាដែលមិនជួយដល់ការច្នៃប្រឌិតគឺ៖

ក. ស្វែងរកលក្ខណៈពិសេសរបស់យើង

ខ. ទទួលយកពត៌មានរបស់អ្នកដទៃ

គ. ប្រឹងប្រែងធ្វើការដោយមិនគិតពីសុខភាព

ឃ. បើកចិត្តឱ្យទូលាយ

១៣០. កត្តាដែលជំរុញឱ្យមានទន្ទានទុនវត្តន៍គឺ៖

ក. កត្តាវិឌ្ឍនៃនៃបច្ចេកវិទ្យា

ខ. កត្តាកំណើនប្រជាជន

គ. កត្តាវិទ្យាសាស្ត្រនិងតម្រូវការ 

ឃ. កត្តាសេដ្ឋកិច្ច

១៣១. រចនាសម្ព័ន្ធលទ្ធផលដែលកើតចេញពីការធ្វើនវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈគឺ៖

ក. ប្រសិទ្ធភាព ភាពសក្តិសិទ្ធិ គណនេយ្យភាព តម្លាភាព និរន្តរភាព

ខ. ការពេញចិត្តពីប្រជាពលរដ្ឋ

គ. ការពេញចិត្តពីមន្ត្រីផ្តល់សេវាសាធារណៈ

ឃ. របៀបការងារងាយស្រួលជាងមុន

១៣២. សកម្មភាពក្នុងចំណោមសកម្មភាពដូចខាងក្រោមនេះនឹងត្រូវចាត់ទុកថាជាការគំរាមកំហែងលើសវនករក្នុងការផ្តល់សេវាកម្ម

ក. អតិថិជនម្នាក់ផ្តល់នូវភាគរយខ្ពស់នៃថ្លៃសេវាកម្មសរុប

ខ. សមាជិកនៃក្រុមសវនករគឺជាប់ពាក់ព័ន្ធនឹងអ្នកគ្រប់គ្រងអតិថិជន

គ. សវនករមានសក្តានុពលជាមួយអតិថិជននិងមានការធានាសេវាសវនកម្មជាមួយអតិថិជន

ឃ. សវនករដើរតួនាទីជាអ្នកតស៊ូមតិក្នុងនាមជាអតិថិជន

១៣៣. ចម្លើយដែលត្រូវក្នុងការធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងហានិភ័យដូចខាងក្រោមគឺ៖

ក. កង្វះខាតការបែងចែកការកិច្ច

ខ. ការព្យាករណ៍សុទិដ្ឋិនិយមដែលបានបង្ហាញដល់ក្រុមអ្នកវិភាគ

គ. ការកាត់បន្ថយក្នុងការធ្វើតេស្តសំខាន់ៗនៅពេលធ្វើសវនកម្ម

ឃ. ការកាត់បន្ថយទំហំការងារក្នុងសវនកម្មផ្ទៃក្នុង

១៣៤. ក្រសួងដែលមានសិទ្ធិចុះអធិការកិច្ចប្រើប្រាស់ធនធានមនុស្សគឺ:

ក. ក្រសួងអប់រំ យុវជន និងកីឡា

ខ. ក្រសួងមុខងារសាធារណៈ

គ. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឃ. ក្រសួងទំនាក់ទំនងរដ្ឋសភា ជាមួយព្រឹទ្ធសភា និងអធិការកិច្ច

១៣៥. សវនករដែលបានអនុវត្តក្នុងពេលបច្ចុប្បន្ន ត្រូវបែងចែកជា:

ក. សវនករបែងចែកជា ២ ប្រភេទ

ខ. សវនករបែងចែកជា ៣ ប្រភេទ

គ. សវនករបែងចែកជា ៤ ប្រភេទ

ឃ. សវនករបែងចែកជា ៥ ប្រភេទ

សូមរង់ចាំសំណួរ ចម្លើយ បន្តបន្ទាប់ទៀត!